មជ្ឈមណ្ឌលឯកសារកម្ពុជា

DOCUMENTATION CENTER OF CAMBODIA

DW Akademie

**គេហទំព័រថ្មីដើម្បីអប់រំយុវជនកម្ពុជាអំពីរបបខ្មែរក្រហម**

ថ្ងៃទី៧ ខែមករា ឆ្នាំ២០១៧ ក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា - ដើមឆ្នាំនេះ មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលជាបណ្ណាសារដ្ឋានតំកល់ទុកឯកសារខ្មែរក្រហមឈានមុខក្នុងពិភពលោក នឹងចាប់ផ្តើមដំណើរការគេហទំព័រថ្មី ដើម្បីអប់រំយុវជនកម្ពុជា ស្តីពីព័ត៌មានដ៏សម្បូរបែបនៃប្រវត្តិសាស្ត្រខ្មែរក្រហម។ គោលបំណងរបស់គេហទំព័រនេះ គឺដើម្បីឆ្លុះបញ្ចាំងពីសម័យកាលដ៏ខ្មៅងងឹតក្នុងប្រវត្តិសាស្ត្រកម្ពុជា ដើម្បីឲ្យក្លាយជាចំណាប់អារម្មណ៍របស់យុវជនកម្ពុជា ជំនាន់ក្រោយ។ គេហទំព័រនេះ នឹងចែករំលែកឯកសារដ៏សម្បូរបែបដែលមានចំនួនមួយលានឯកសារ តម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលជាបណ្ដុំឯកសារពាក់ព័ន្ធពីអំពើប្រល័យពូជសាសន៍ដ៏ធំបំផុតក្នុងតំបន់អាស៊ីអាគ្នេយ៍។

ឯកឧត្តមបណ្ឌិត ហង់ ជួនណារុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា បានយល់ស្របពីសារៈសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រ ដោយមានប្រសាសន៍ថា៖ *«ការសិក្សាអំពីប្រវត្តិសាស្ត្រខ្មែរក្រហម គឺមិនត្រឹមតែមានសារៈសំខាន់ដល់យុវជន ដើម្បីឲ្យយុវជនបានយល់ដឹងអំពីប្រវត្តិសាស្ត្រសម័យទំនើបរបស់កម្ពុជាតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចយល់ដឹងអំពីដើមហេតុនិងផលវិបាកនៃសោកនាដកម្មក្នុងប្រទេសកម្ពុជា ក៏ដូចជាការទប់ស្កាត់មិនឲ្យប្រវត្តិសាស្ត្របែបនេះ កើតឡើងជាថ្មីម្តងទៀតនាថ្ងៃអនាគត»*។

ក្រោមជំនួយឧបត្ថម្ភពីអង្គការអភិវឌ្ឍន៍ប្រព័ន្ធផ្សព្វផ្សាយអាល្លឺម៉ង់(DWAkademie)គេហទំព័រថ្មីនេះនឹងបង្ហាញព័ត៌មានខ្មែរក្រហមនៅតាមឧបករណ៍ផ្សព្វផ្សាយព័ត៌មានយ៉ាងទូលំទូលាយ។ អ្នកប្រើប្រាស់អាចស្វែងរក( ព័ត៌មាន ) តាមរយៈខ្សែភាពយន្តប្រវត្តិសាស្ត្រ ឯកសារជាសម្លេង រូបភាពដ៏កម្រ និង បទសម្ភាសន៍ក្នុងពេលបច្ចុប្បន្ន ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហមនៅក្នុងទូទាំងប្រទេស។ គេហទំព័រនេះ នឹងមានផ្នែកៗដូចជា ការសង្ខេបព្រឹត្តិការណ៍សំខាន់ៗចាប់តាំងពីថ្ងៃកកើតដំបូងនៃរបបខ្មែរក្រហម រហូតដល់ដំណើរការរៀបចំតុលាការដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម សព្វវចនាធិប្បាយនៃគោលនយោបាយនិងការអនុវត្តន៍ជាស្តែងរបស់កម្ពុជាប្រជាធិបតេយ្យ និងជីវប្រវត្តិរបស់អ្នករស់រានមានជីវិតនិងអ្នកស្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

ប្រជាជនប្រមាណជាង១លាន៧សែននាក់ ត្រូវបានជឿជាក់ថា បានស្លាប់ដោយសារការអត់ឃ្លាន ការធ្វើការហួសកម្លាំង និងការសម្លាប់ នៅក្នុងចន្លោះឆ្នាំ១៩៧៥ ដល់ ១៩៧៩។ ប្រជាជនជាច្រើនលាននាក់ទៀតត្រូវបានបាត់បង់សិទ្ធិនៅក្នុងការប៉ុនប៉ងបន្សុទ្ធសង្គម ឲ្យទៅជារដ្ឋកសិកម្មយ៉ាងបរិសុទ្ធបែបជ្រុលនិយមរបស់អង្គការ ដែលចង់ឲ្យមានការរស់តាមរបៀបខ្លួនទីពឹងខ្លួន។

គេហទំព័រថ្មីនេះ នឹងធ្វើកិច្ចការបន្ថែមទៅលើបេសកកម្មអប់រំរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលធ្វើការងារផ្ទាល់ ស្របតាមសម្តីរបស់អ្នកនិពន្ធពានរង្វាន់ណូបែល វីល្លាម ហ្វូលក៏ណឺ ដែលបាននិយាយថា៖ *«អតីតកាលគឺមិនចេះស្លាប់ឡើយ ហើយអតីតកាលក៏មិនមែនជាអតីតកាលទេ»*។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលជំនួយទ្រទ្រង់ថវិកាសម្រាប់រយៈពេលវែង ពីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិសម្រាប់បំពេញបេសកកម្មរបស់ខ្លួន។

លោក ផេង ពង្សរ៉ាស៊ី ប្រធានគម្រោងស្តីពីការសិក្សាអំពើប្រល័យពូជសាសន៍នៅកម្ពុជា បានដកស្រង់សម្តីមកនិយាយថា៖ *«ទស្សនៈរបស់យើងពីអតីតកាល មានឥទ្ធិពលដល់ការឆ្លើយតបរបស់យើងចំពោះកាលៈទេសៈនាពេលបច្ចុប្បន្ន។ ប្រសិនបើយើងគិតខុសពីប្រវត្តិសាស្ត្រ យើងប្រហែលជាអាចធ្វើការជ្រើសរើសខុសនៅថ្ងៃនេះ»*។

មជ្ឈមណ្ឌលឯកសារកម្ពុជា

DOCUMENTATION CENTER OF CAMBODIA

DW Akademie

គោលបំណងមួយក្នុងចំណោមគោលបំណងចម្បងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺដើម្បីថែរក្សាប្រវត្តិសាស្ត្រឲ្យនៅមានជីវិត និងធ្វើយ៉ាងណាឲ្យប្រវត្តិសាស្ត្រនេះផ្សារភ្ជាប់ជាមួយនឹងជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជាទាំងអស់ ដែលក្នុងនោះមានប្រមាណ៧០ភាគរយ គឺជាអ្នកកើតក្រោយរបបខ្មែរក្រហម។

លោក ខាយល៍ ចេមស៍ (Kyle James) ជាទីប្រឹក្សាការងាររបស់អង្គការអភិវឌ្ឍន៍ប្រព័ន្ធផ្សព្វផ្សាយអាល្លឺម៉ង់ DW Akademie ដែលបានធ្វើការរួមគ្នាជាមួយមជ្ឈមណ្ឌលឯកសារលើគម្រោងនេះ បានថ្លែងថា៖ *«គេហទំព័រអន្តរកម្មថ្មីនេះ នឹងដើរតួជាយានផ្តល់ព័ត៌មានលើប្រធានបទសំខាន់ៗ ដល់យុវជនកម្ពុជា»។* លោកបានបន្ថែមថា គេហទំព័រនេះនឹងធ្វើឲ្យការប្រើប្រាស់(គេហៈទំព័រ)តាមទូរស័ព្ទដៃ ដែលមានភាពងាយស្រួល។

គេហទំព័រនេះ ត្រូវបានរៀបរៀង និងបង្កើតឡើងដោយ Endorphine ជាភ្នាក់ងារបង្កើតគេហទំព័រ មានមូលដ្ឋាននៅទីក្រុងភ្នំពេញ មានតួនាទីយ៉ាងសកម្មក្នុងការបង្កើតទំនាក់ទំនងផ្នែកឌីជីថល ដែលកំពុងរីកដុះដាលនៅកម្ពុជា។ ក្រោយពីការសាកល្បងជំហានទីពីរនៃការអភិវឌ្ឍន៍ការងារនៅដើមឆ្នាំ២០១៧ខាងមុខនេះ គេហទំព័រនេះនឹងធ្វើការសាកល្បងប្រើប្រាស់ជាមួយក្រុមយុវជនជាច្រើនក្រុម មុនពេលដែលគេហទំព័រនេះត្រូវបានដាក់ឲ្យដំណើរការជាសាធារណៈ៕

ទំនាក់ទំនង៖


**ផេង ពង្សរ៉ាស៊ី**
ប្រធានក្រុម
គម្រោងស្តីពីការសិក្សាអំពើប្រល័យពូជសាសន៍នៅកម្ពុជា
**មជ្ឈមណ្ឌលឯកសារកម្ពុជា**
Truthrasy.p@dccam.org
www.dccam.org
ភ្នំពេញ កម្ពុជា
ទូរស័ព្ទ៖ +៨៥៥ ១២ ៦៩៦ ៩៦១

**ខាយល៍ ចេមស៍**
ទីប្រឹក្សាអង្គការ
DW Akademie
kyle@kylejames.net
www.dw-akademie.com
ទីក្រុងបោន អាល្លឺម៉ង់
ទូរស័ព្ទ៖ +៤៦ ៧២ ៣២៤ ១៩៦៦